ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដែលហៅកាត់ថាអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**.។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបច្ចេកទេសដែលធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់**គ.ជ.គ.ក**.
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទទួលបានការយល់ព្រមពី**គ.ជ.គ.ក**. ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- គ្រប់គ្រងហិរញ្ញវត្ថុរបស់ **គ.ជ.គ.ក**.
- ពិនិត្យតាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូចជូន**គ.ជ.គ.ក**.
- សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ
- ធ្វើរបាយការណ៍ជូន**គ.ជ.គ.ក**.
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែល**គ.ជ.គ.ក**.ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែកគោលនយោបាយ
- ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ផ្នែកពិនិត្យតាមដាននិងវាយតម្លៃ។

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនតាមការចាំបាច់។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៤._**

ផ្នែកគោលនយោបាយមានតួនាទីនិងភារកិច្ចៈ

- លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូចជូន **គ.ជ.គ.ក**.
- សម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យដើម្បីអភិវឌ្ឍសមត្ថភាពដល់អ្នកពាក់ព័ន្ធ
- សហការជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីធានាប្រសិទ្ធភាពការងាររបស់**គ.ជ.គ.ក**.
- សិក្សាស្រាវជ្រាវពីការគាំពារនិងការអភិវឌ្ឍកុមារតូចដើម្បីចងក្រងជាឯកសារសម្រាប់ជាធនធានដល់អ្នកសិក្សាស្រាវជ្រាវ
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដើម្បីពង្រីកការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច
- សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ ដើម្បីធានាការអនុវត្តតួនាទីនិងភារកិច្ចដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**. ប្រគល់ជូន។

**មាត្រា ៥._**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចៈ

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលទទួលបានការយល់ព្រមពី**គ.ជ.គ.ក**. ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- បូកសរុបការងារពាក់ព័ន្ធនឹងការគាំពារនិងការអភិវឌ្ឍកុមារតូចដាក់ជូន**គ.ជ.គ.ក**. ដើម្បីពិនិត្យនិងសម្រេច
- បំពេញការងាររដ្ឋបាលនិងធានានិរន្តរភាពការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាន **គ.ជ.គ.ក**.
- រៀបចំនិងចាត់ចែងកិច្ចប្រជុំរបស់**គ.ជ.គ.ក**.
- ធ្វើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក**.
- គ្រប់គ្រងចំណូល ចំណាយ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់**គ.ជ.គ.ក**.
- រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌចលនទ្រព្យនិងអចលនទ្រព្យរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានសម្រាប់រយៈពេលខ្លី មធ្យម និងវែង

- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍ និងលើកអនុសាសន៍ជូន**គ.ជ.គ.ក.** ពិនិត្យនិងសម្រេច
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** ប្រគល់ជូន។

**មាត្រា ៦.-**

ផ្នែកពិនិត្យតាមដាននិងវាយតម្លៃ មានតួនាទីនិងភារកិច្ចដូចតទៅៈ

- សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យសម្រាប់ការពិនិត្យតាមដាននិងការវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- ស្រាវជ្រាវនិងកំណត់សូចនាករចំណុចដៅសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃ
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍ ដើម្បីកែលម្អយន្តការពិនិត្យតាមដាននិងវាយតម្លៃ
- ប្រមូលទិន្នន័យនិងវិភាគលើលទ្ធផលការអនុវត្តគ្រប់កម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច ដើម្បីដាក់ជូន**គ.ជ.គ.ក.** ពិនិត្យ
- ផ្សព្វផ្សាយលទ្ធផលនៃការពិនិត្យតាមដាននិងការវាយតម្លៃដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** ប្រគល់ជូន។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** មានមន្ត្រីបម្រើការមកពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** អាចមានអ្នកជំនាញការនិងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

**មាត្រា ៨.-**

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីនិងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.**។

បែបបទនិងនីតិវិធីអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋាន**គ.ជ.គ.ក.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១៣
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

### អង្គការលេខនៃអគ្គលេខាធិការដ្ឋាន គ.ជ.គ.ក.




**សម្គាល់**

- ទំនាក់ទំនងប្រយោល ┈┈┈▶
- ទំនាក់ទំនងផ្ទាល់ ──▶
- គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច(**គ.ជ.គ.ក.**)